«កូនស្រីខ្ញុំស្លាប់ដោយអយុត្តិធម៌ណាស់ ខ្ញុំមិនអស់ចិត្តទេ!»

«ធ្វើតាមយើងបង្គាប់ឯងអាជា! នេះជាវិធីសាស្ត្រគ្រប់គ្រងនៃវិញ្ញាណដែលមានឥទ្ធិពលខ្លាំងមិនធ្លាប់មាន ព្រោះកូនឯងស្លាប់ចំថ្ងៃខ្មោច យប់រនោច និងអន្ធការវេលា១០០០ឆ្នាំ»

«ខ្ញុំចង់ឱ្យក្រវ៉ាន់រស់ឡើងវិញ!»

«ហាសហា! គ្មានមន្តណាអាចធ្វើឱ្យអ្នកស្លាប់រស់ឡើងវិញទេអាជា! តែគ្រូឱ្យកូនស្រីឯងក្រោកមកវិញបាន តែមិនដូចមុនឡើយ!»

«អ្វីក៏ដោយៗ!.....អ្វីក៏ដោយលោកគ្រូ»

---

ខេត្តតាកែវ ឆ្នាំ១៩៥៥....

«សក់មនុស្ស ក្រចក ស្បែកខ្លះនៃរាងកាយ និងឈាមកកត្រូវបានគេរកឃើញក្នុងកែវនេះ!»

ទុំនាង ជាឈ្មោះរបស់អធិការព្រហ្មទណ្ឌដែលទើបផ្លាស់មកប្រមាណបីថ្ងៃ។

សំណុំរឿងមនុស្សស្លាប់នៅផ្ទះអភិបាលលោកមនោជារឿងដែលនាងកំពុងកាន់។ អធិការមានវ័យ៣៣ឆ្នាំ ជាមេម៉ាយមានកូនប្រុសម្នាក់។ នាងពាក់ស្រោមដៃប្រញាប់ប្រញាល់ទទួលក្រឡមកពិនិត្យ។

«ពិតជាគួរឱ្យខ្ពើម!»

នាងភ្លាត់មាត់។ ដឹងថាខ្លួនបានជ្រុលសម្តីហើយក៏ងាកទៅបញ្ជា។

«បញ្ជូនទៅវិភាគ!»

ឧត្តមសេនីយ៍វ៉ារុធ គឺជាប្រធានផ្នែកស៊ើបអង្កេតព្រហ្មទណ្ឌ បានប្រាប់អធិការស្រីតាំងពីភ្នំពេញមកថា ករណីនេះគឺមានសារៈសំខាន់ ដោយសារអ្នកស្រុកមុំនេះកំពុងរស់នៅរួញក្នុងភាពភ័យខ្លាច។

«មានសាកសពស្លាប់កើតឡើងបីជាប់ៗគ្នានៅទីនេះ! ហេតុការណ៍ត្រូវបានកត់ត្រាថា កើតឡើងរហូតដល់មានស្លាប់ក្នុងរយៈពេលប្រមាណជាបីខែមកនេះ!»

«បីខែស្លាប់បីនាក់?» អធិការទុំនាងសួរដោយចងចិញ្ចើមងាកមកអ្នកដែលរាយការណ៍។ ជាកូនប៉ូលិសមុខភ័យស្លេក សម្បុរសណ្ដែកបាយឈ្មោះចូច។

«បាទទាន! ចំណែកឯអ្នកគន់គូរផ្នែកហោរាសាស្ត្រនិងមើលផ្លូវងងឹត ដែលអ្នកស្រុកគេជឿងប់ងល់នៅតំបន់នេះបានជឿជាក់ថា មានបណ្ដាសាមួយពាក់ព័ន្ធជាមួយនឹងផ្ទះរបស់លោកអភិបាលមនោ!»

«អភិបាលមនោជាអ្នកណា?»

ចូចឱនមកលើកដៃខ្សឹបក្បែរត្រចៀកមេះ

«ម្ចាស់ផ្ទះនេះ តាំងពីតយូរមក! រូបនេះជារូបកូនស្រីគាត់ ក៏ជាប្រពន្ធម្ចាស់ផ្ទះបច្ចុប្បន្ន!»

«ម្ចាស់ផ្ទះតាំងពីយូរនិងម្ចាស់ផ្ទះបច្ចុប្បន្ន?! អត់យល់!»

«បាទ បានសេចក្ដីថាដំបូងអភិបាលនេះជាពោះម៉ាយស្គុក រស់នៅពីរនាក់មានកូនក្រមុំម្នាក់ ជាកូនតែម្នាក់គត់ឈ្មោះក្រវ៉ាន់! ចំណែកក្រោយកូនរៀបការ គាត់ប្រគល់ផ្ទះនេះឱ្យ!»

អធិការដើរសំដៅគំនូរមនុស្សស្រីកាន់ចង្កៀងម៉ាងសុង។ គំនូរនេះធំណាស់និងសឹងគ្របដណ្ដប់មួយកំណាត់ជញ្ជាំងផ្ទះ។

«ហេតុអីបានជាគូររបៀបហ្នឹង?»

អធិការទន្ទេញតិចៗ ព្រោះស្ត្រីក្នុងគំនូរកំពុងតែឈានជើងចេញពីគំនូរមួយទៀតមកក្រៅ។

«ដុតចោលទៅ! ដុតចោលទៅសែហ្វ!»

នាងបែរក្រោយ ព្រោះ«សែហ្វ»គឺសំដៅនាង។

មីងម្នាក់មុខខ្មៅឈរក្ដាប់ដៃនៅទ្វារសម្លឹងមកដោយទទូចសុំអន្តរាគមន៍។

«ដុតរូបនេះចោលទៅទាន! ដុតវាទៅ!»

គាត់និយាយទៀត។ អធិការទុំនាងងាកមកសម្លឹងចូច។

ចូចឱនខ្សឹបៈ

«មានតំណាលថា រាល់រនោចធំ! នាងយំ ហើយដើរចេញមកពីផ្ទាំងគំនូរ!»

ទុំនាងចងចិញ្ចើម។

«សូត្រកំណាព្យស្អីមិញនេះចូច?!»

«មិនមែនកំណាព្យទេទាន! អ្នកស្រុករាយការណ៍ថា រាល់១៣ទៅ១៥រោច ផ្ទះនេះទុកចោលគ្មានមនុស្សនៅទេ!!! គេឆ្លើលថា....!»

គូកនចូចជាមនុស្សប្រុសស្គមទាបម្នាក់ឈ្មោះនិមល បានឱនមកខ្សឹបដាក់ត្រចៀកមេស្រីម្នាក់នេះជំនួសវិញថាៈ

«ទាន ការសួរចម្លើយអ្នកស្រុកនៅក្បែរៗនិងអ្នកបម្រើពីរនាក់នៅក្នុងផ្ទះបានប្រាប់ថា ម្ចាស់ផ្ទះថ្មីឈ្មោះសៀង មិនដែលនៅផ្ទះទេ រៀងរាល់ថ្ងៃរនោចចាប់ពីដប់បីរហូតដល់ដប់ប្រាំរោច! ផ្ទះនេះមិនមានអ្នកណានៅដាច់ខាត ដូចគ្នាអ្នកបម្រើទាំងអស់ធ្វើការតែធម្មតាពេលថ្ងៃ ហើយក៏ត្រលប់ទៅផ្ទះរបស់គេវិញនៅពេលយប់! មីងនោះឈ្មោះឈឿន ជាអ្នកបម្រើថ្មី!»

អធិការងាកមករកមីងឈឿន មាត់នាងពោលខ្សឹបៗដាក់និមលៈ

«ចម្លែកម្ល៉េះ? នាំគាត់ចាំខ្ញុំក្នុងបន្ទប់មួយទៀត ខ្ញុំសួរផ្ទាល់!»

និមលរត់ទៅ ចូចឆ្លៀតឱនខ្សឹបៈ

«របាយការណ៍ចាស់នៅផ្ទះនេះទាន!»

ទុំនាងទទួលយកមកអានពិនិត្យ។ អធិការលូកទាញយកក្រដាសប៉ុន្មានសន្លឹកដែលត្រូវបានវាយដោយអង្គុលីលេខមកឱនសម្គាល់ហ្មត់ចត់។

«អ្នកស្លាប់ទាំងបីនាក់ទាំងលើកនេះ!»

ចូចខ្សឹបមកធ្វើឱ្យនិមលនិងមេកោយងើបមើលមុខគ្នា។

ចូចនិយាយរាយការណ៍ទៀត៖

«ឈ្មោះមុំ ឈ្មោះគន្ធី ហើយនិងថាវី ស្លាប់នៅថ្ងៃដប់ប្រាំរោចដូចគ្នាបេះបិទ!»

«អ្នកក្រោយគេនេះឈ្មោះធី?»

«បាទឈ្មោះរុង សុគន្ធី អាយុ១៩ឆ្នាំ! ជាអ្នកថៃទាំត្រី!»

«ត្រី?!»

ទុំនាងងាកទៅឃើញអាវកញ្ចក់ធំមួយ ចាំងមកពីបន្ទប់មួយទៀតនៅខាងឆ្វេងផ្ទះ។ វាជាបន្ទប់លៀងសាយភោជនព្រោះមានតុវែងធំនិងកៅអីជាង១០កន្លែងព័ទ្ធជុំវិញ។

សែហ្សដើរទៅពិនិត្យ។ ក្នុងបន្ទប់នេះពិតជាមានគំនូរប្រណីត ទូសៀវភៅ សម្ភារៈបុរាណ និងមានឧបករណ៍ចាក់រៀល(ឌីសធំៗកាលជំនាន់នោះ)និងការតុបតែងចោមព័ទ្ធដោយផើងត្រី។

«ប្តីអ្នកស្រីក្រវ៉ាន់ជាមន្ត្រីជលផល ឈ្មោះពេញគឺ ឃ្លាំង សៀងសក្តិ គេហៅថាលោកសៀងៗ ជាមនុស្ស....»

ឈប់មាត់ឈឹង....ធ្វើឱ្យអធិការទុំនាងងាកមកមើលមុខ....

«និយាយៗអស់ថ្ម?!»

ចូចអេះក្បាល ហើយម្តងម្កាលងើបមុខស៊ីញ៉ូនិមលឱ្យនិយាយម្តង។

និមលក៏ចូលមកបន្ត៖

«ខ្ញុំបានចេញឆែកពិនិត្យគ្រប់បរិវេណជុំវិញផ្ទះហើយ គ្មានអ្វីប្លែកទេ! គ្មានសញ្ញាកាច់សោចូល គ្មានស្នាមលុកចូល ឃាតកៈអាចជាមនុស្សនៅក្នុងនេះ!»

«ចុះយប់កើតហេតុអ្នកណានៅខ្លះ?»

«អត់ទេទាន ដូចជម្រាប! ពី១៣ដល់១៥រោចគ្មានអ្នកណានៅ....អី មានពាក្យខ្សឹបខ្សៀវថា គេតែងតែឮសូរមនុស្សស្រីយំនៅផ្ទះនេះនៅរៀងរាល់យប់ដែលគ្មានមនុស្សនៅ គឺរនោចពី១៣ដល់១៥!»

«ចុះបើអត់អ្នកនៅផង ម៉េចក៏មានអ្នកស្លាប់?!»

ចូចច្បូតមុតចុះឡើងមិននិយាយ ទុកឱ្យនិមលបន្តះ

«គ្មាននរណាផ្តល់ព័ត៌មាននៅឡើយទេសែហ្វ ថាហេតុអីបានជាអ្នកសម្អាតនិងថៃត្រីមកស្លាប់នៅក្នុងផ្ទះនេះយប់មិញ ព្រោះធម្មតានាងសុគន្ធីមិនធ្វើការឡើយ ពីថ្ងៃសុក្រដល់ថ្ងៃអាទិត្យ! វេនរបស់គាត់គឺរៀងរាល់ថ្ងៃចន្ទហើយនិងថ្ងៃព្រហស្បតិ៍!»

ទុំនាងងក់ក្បាលះ

«ឯណាមីងមិញ?!»

ពួកគេបង្ហាញផ្លូវថ្នាក់ដឹកនាំស្រី នាងអធិការក៏ដើរទៅដល់បន្ទប់ផ្ទះបាយមួយទៀត។

«មីងឈ្មោះឈឿន?»

ស្ត្រីនេះមានសភាពដូចជាបាក់ស្បាតក្នុងការភ័យខ្លាច។ គាត់អង្គុយក្តាប់ម្រាម១០ចូលគ្នាចុះឡើងៗលើកៅអីមួយ។

អធិការទាញកៅអីមួយទៀតមកអង្គុយដោយមានកូនចៅទាំងពីរនៅពីក្រោយចាំកត់ត្រា។

«ម៉េចបានមីងស្អប់រូបនោះ? ក្រែងជាជាចៅហ្វាយស្រី?!»

ញ័រមាត់ដោយការភ័យខ្លាចះ

«មិនដែល....មិនដែលស្គាល់ជំទាវក្រវ៉ាន់ទេ គាត់ស្លាប់យូរហើយ ខ្ញុំទើបមកចូលធ្វើការបាន២១ថ្ងៃ!»

«មិញនេះនៅក្រៅមីងឱ្យខ្ញុំដុតរូបនេះ?!»

«វាមិនមែនគំនូរធម្មតាទេ វាជាបណ្តាសា! វានឹងធ្លាក់មកលើគ្រួសារមេប្រុស ឬកូនចៅគាត់រហូតនាពេលអនាគត!»

ស្ត្រីកាន់តែញ័រ....អធិការសួរឡើងះ

«មីងឈឺ?!»

«អត់ទេ.....ខ្ញុំភ័យ!»

«និយាយទៀតបានទេ!»

«ខ្ញុំត្រូវតែនិយាយ!»

«និយាយមកអ៊ីចឹង! កំណាព្យមានតំណាលថា វាល់រនោចធំ! នាងយំហើយដើរចេញមកពីផ្ទាំងគំនូរ! ជាកំណាព្យអ្វី»

គាត់ស្ទុះក្រោក ធ្វើឱ្យអធិការត្រូវងើយទាំងភ្ញាក់ផ្អើល។ ចូចខំរារាំង៖

«អង្គុយចុះសិនមីង!»

«មិនមែនកំណាព្យទេសៃហ្វ! វាជាការពិត! គំនូរនេះមានបូជាចារ្យអាថ៌ន ពាក្យសម្បថនេះនិងវិញ្ញាណខ្មោចត្រូវបានគេចិញ្ចឹមក្នុងនេះ!»

សៃហ្វឱនមុខគិត ធ្វើដូចជឿទាំងនាងគិតថា«ពិតជាឆ្កួត»។

«មេប្រុសពិតជាមានទ្រព្យសម្បត្តិច្រើនណាស់! ជាការលំបាកខ្លាំងណាស់ក្នុងការឱ្យគាត់មិនខូចស្រី! តែនេះប្រពន្ធគាត់ស្លាប់ទៅហើយ គាត់គេចមិនផុតពីមានអ្នកក្រោយទេ!»

«ខ្ញុំមិនយល់!» អធិការមមីរភ្នែកសម្លឹងមីង។

មីងឈឿនជូតទឹកភ្នែក៖

«គេថាមកពីគាត់ក្បត់ប្រពន្ធ! អ្នកស្លាប់ទាំងបីជាអ្នកដែលមេប្រុសស្រឡាញ់ចង់យកជាប្រពន្ធក្រោយ!ហើយពួកគេស្លាប់ ព្រោះជាប់ពាក់ព័ន្ធនឹងបណ្តាសា!»

នៅតែមិនយល់រឿងច្រើនទេ ទោះមានតម្រុយខ្លះជាមូលដ្ឋានយកមកគិតបាន អធិការងាកមើលមុខចូច។

ចូចឆ្លើយ៖

«នេះជាអ្វីដែលខ្ញុំចង់ជម្រាបនៅក្រៅមិញទាន! ឈ្មោះសៀងជាប្ដី ជាមនុស្សមានប្រវត្តិស្រីញី ច្រើន! ជនរងគ្រោះ មុំ អាយុ១៨ឆ្នាំ ជាគ្រូបឋម មានរូបរាងស្អាតសោភា ជាមនុស្សដែលទាក់ទង ស្នេហាលួចលាក់ជាមួយម្ចាស់ប្រុសផ្ទះនេះក្រោយប្រពន្ធស្លាប់! ចំណែកថាវី ជាអ្នកបម្រើថ្មី អាយុ១៦ឆ្នាំ ជាកូនអ្នកបម្រើចាស់ម្នាក់ តែក៏មានគេឃើញថាវីបានឡើងទៅជិះទូកដើរលេង ជាមួយឈ្មោះសៀង ដោយស្លៀកពាក់ឆើតសប្បាយលក្ខណៈគូស្នេហ៍ថ្មី!»

«របាយការណ៍មុនៗមិនពិស្ដារច្បាស់លាស់ចំណុចទាំងអស់ហ្នឹងអ៊ីចឹង?!» ទុំនាងសួរទាំងចង ចិញ្ចើម។

«ភាគច្រើនគ្រួសារអ្នកស្លាប់ ដូចមិនព្រមសហការជាមួយអាជ្ញាធរ!»

អធិការគិតស្ងាត់បន្តិចងាកមកមីងនេះវិញ ដោយសួរគាត់៖

«ហេតុអ្វីយើងត្រូវដុតរូបនេះ?»

មីងឈឿនក្រឡេកក្រឡាប់ភ័យ។

មាត់គាត់ញ័រតតាត់៖

«មានបណ្ដាសាផ្ចប់...នៅលើ...នៅលើនោះដើម្បីគ្រប់គ្រងវិញ្ញាណម្ចាស់រូបឱ្យចេញមកសម្លាប់ មនុស្សបាន! រឿងរ៉ាវគំនូរនេះ មិនធម្មតាទេ ម្ដាយរបស់ថាវីឈ្មោះមីងវិន គាត់អ្នកហៅខ្ញុំមកធ្វើ ការនៅផ្ទះនេះ គាត់និយាយថា ដោយសារតែបណ្ដាសាចាស់មួយ ឪពុកអ្នកក្រវ៉ាន់បានដាក់ឱ្យ កូនគាត់មិនទៅចាប់ជាតិទេ! រាល់រនោចធំ ជំទាវចេញពីរូបមកក្រៅបាននិងសម្លាប់មនុស្ស...!»

អធិការក្រពាត់ដៃញឹមៗ។

នាងសិក្សានៅបារាំងនិងមានគំនិតផ្អែកលើវិទ្យាសាស្ត្រ។ កាយវិការនាងមិនព្រមទទួល ស្គាល់ព័ត៌មាននេះទេ តែនាងមិនបង្ហើបគំនិតចេញ ព្រោះចង់ឮទៀត។

«និយាយទៀតបាន!» សែហ្វស្រីតឿនឡើង។

«វាជាមន្តអាគម វាគឺជាមហិទ្ធិឫទ្ធិដោយការប្រើបណ្ដាសាអាក្រក់ គ្រប់គ្នាភ័យខ្លាចណាស់! វា ពិតជាអាក្រក់ណាស់! ដុតចោលទៅសែហ្វ»។

ទុំនាងងាកមកសួរនិមល៖

«គំនូរនោះមានអីប្លែក?!»

និមលគ្រវីក្បាល៖

«ធម្មតា!»

ចូចលូកមាត់៖

«តែឈរមើលទៅដូចព្រីម៉េចទេ!»

អធិការងាកមកសួរមីងវិញ៖

«ចុះមីងដឹងរឿងកូនស្រី១៦ឆ្នាំរបស់មិត្តមីងទេ? ថាវីមកបម្រើនៅទីនេះបានប៉ុន្មាន? ហើយបានជិះទូកមែនអត់?!»

មីងស្រែកយំ៖

«ខ្មោចប្រពន្ធគាត់ជាមនុស្សប្រចណ្ឌ តែប្ដីជាមនុស្សល្មោភកាម!»

អធិការលើកម្រាមស្ដាំទាំងប្រាំមកខ្ទប់មាត់។ តាមពិតសែហ្វកំពុងគិតពីការរន្ធត់ដែលមីងឈឿននិយាយដាច់ៗ។

និមលតឿន៖

«និយាយឱ្យស្រួលតាមសំណួរគាត់ទៅមីង! ថាវីមកបម្រើនៅទីនេះបានប៉ុន្មាន? ហើយបានជិះទូកជាមួយចៅហ្វាយប្រុសមែនអត់?!»

«ចៅហ្វាយស្រឡាញ់ចង់លើកថាវីជាប្រពន្ធចុង!»

ចូចឱនមកខ្សឹប៖

«មានរបាយការណ៍ នៅយប់ដែលស្លាប់ ថាវីនៅក្នុងសណ្ឋាគារតាមបម្រើឈ្មោះសៀង! អត់មកដេកផ្ទះទេតែព្រឹកឡើងមិនដឹងយ៉ាងម៉េចបានជាមកដេកស្លាប់នៅក្នុងសួន! ពេលម្ដាយមកបើករបងចូលធ្វើការឃើញកូនស្រីចងកក្រោមដើមចំប៉ា!»

«ខ្មោចធ្វើ! អ្នកស្រីក្រវ៉ាន់ធ្វើៗៗៗ!»

មីងឈឿនស្រែកបែបនេះទាល់ដួលសន្លប់ខ្លួនឯង។

---

សែហ្វនិងកូនចៅទាំងពីរបានមកដល់ផ្ទះតូចមួយក្បែរជើងភ្នំជីសូរ។ ក្នុងចម្ការជ្រៅមួយ ពួកគេបានជួបជាមួយយាយចំណាស់ម្នាក់។

គាត់ក្អកខេះៗ ហើយរាយការណ៍៖

«ចាំ....ខ្ញុំស្គាល់មនោនេះ! ប្រហែលជាសាមសិបឆ្នាំមុនកាលខ្ញុំនៅក្មេងធ្លាប់ទៅបម្រើការនៅផ្ទះគាត់ ពេលដែលមានបុណ្យភូមិធំមួយ! កាលនោះ ខ្ញុំទាន់ឃើញកូនស្រីគាត់ តែប្រពន្ធគាត់ស្លាប់ហើយ! កូនឈ្មោះនាងក្រវ៉ាន់នៅតូចណាស់ ទើបតែអាយុ២ឬ៣ឆ្នាំត្រូវម្ដាយស្លាប់ចោលបាត់!»

«ប្រពន្ធគាត់ម៉េចបានស្លាប់?!»

«គ្មានអ្នកណាដឹងទេ! ដឹងតែថា មនុស្សមនោនេះគាត់ស្រឡាញ់ប្រពន្ធកូនខ្លាំង មានទ្រព្យសម្បត្តិច្រើន ចិត្តកំណាញ់បន្តិច! មានអ្នកបម្រើ ចាំធ្វើស្រែចម្ការឱ្យ មានតាំងពីជំនាន់ទាសកររមករាប់សិបនាក់ តែគាត់មិនយកប្រពន្ធថ្មីសូម្បីតែម្នាក់ តស៊ូនៅតែជាមួយនឹងកូនស្រីរហូត! ដល់ពេលអ្នកក្រវ៉ាន់បានពេញក្រមុំអាយុដប់បួនឆ្នាំ ក៏ឪពុកលើកឱ្យរៀបការជាមួយនឹងនិស្សិតមកពីស្រុកបារាំងឈ្មោះសៀងសក្តិ!»

អធិការសួរកាត់៖

«ប្ដីរបស់ជំទាវក្រវ៉ាន់ជានិស្សិតស្រុកបារាំងដែរ? ចម្លែកៗណាស់ ខ្ញុំស្គាល់និស្សិតខ្មែរនៅបារាំងច្រើន ម៉េចរំលងឈ្មោះនេះ?»

លោកយាយក្អកបណ្ដើរប្រាប់បណ្ដើរឡើង៖

«ត្រូវហើយឮសូររៀនសូត្រខាងជលផល ប៉ុន្តែមនុស្សនេះមិនមានពូជត្រកូលធំដុំទេ គ្រាន់តែមានរូបរាងសង្ហា សម្បូរស្រីស្រឡាញ់ច្រើន!»

«បានសេចក្ដីថាម៉េចទៅអ៊ំ?» ចូចតឿនព្រោះជក់សាច់រឿង។

«មានន័យថា ដោយសារតែកូនស្រីរបស់គាត់លង់ស្រឡាញ់មនុស្សនេះខ្លាំង នៅពេលហៅទៅឱ្យបង្រៀនភាសាបារាំងនៅផ្ទះ! កាលនោះឪពុកប្រគល់ទ្រព្យនិងលើកកូនឱ្យទាំងមិនទុកចិត្តនាយនេះអ្វីបន្តិចទេណា ក៏ត្រូវអ្នកភូមិនាំគ្នានិយាយដើមតរៀងមក!»

និមលសួរវិញម្ដង៖

«បើមិនទុកចិត្តទេ ហេតុអីបានជាប្រគល់ផ្ទះទ្រព្យសម្បត្តិថែមទាំងការកូនស្រីឱ្យទៅនៅជាមួយគេ?!»

យាយតបមិនទញ់ទ័លសោះ៖

«ដូច្នេះហើយបានជាគាត់កើតទុក្ខខ្លាំងណាស់ក្រោយៗមក! អ្នកជិតស្និទ្ធរបស់អភិបាលមនោខ្លះបាននិយាយថា គាត់ផឹកស្រាជារៀងរាល់ថ្ងៃរាល់ពេលត្រលប់មកពីលេងកូនស្រីគាត់! ត្រូវដឹងណាសែហ្វ នៅពេលដែលកូនស្រីគាត់ស្លាប់ នាងទើបតែអាយុបានដប់ប្រាំពីរឆ្នាំទេ បានន័យថារៀបការហើយបានបីឆ្នាំក៏ត្រូវប្ដីធ្វើបាបរហូតដល់ស្លាប់!»

អធិការពិតជាភ្ញាក់ផ្អើលខ្លាំងនិងព័ត៌មាននេះ។

«ប្ដីធ្វើបាបរហូតដល់ស្លាប់???? ហេតុអីបានជាមិនមានអ្នកណាប្ដឹងប៉ូលិស?!»

នាងងាកមកសួរគូកន៖

«មានរបាយការណ៍ទេ!»

និមលកំពុងស្រឡាំងកាំងក៏ឆ្លើយទីទើរ៖

«មានទាន! ប៉ុន្តែថាអ្នកក្រវ៉ាន់ឈឺស្លាប់!»

ទំនាងងាកមកមើលមើលសាក្សីជរាវិញ។ ស្ត្រីម្នាក់នេះលើកឡើងមកទៀត៖

«ពិបាកណាស់ ពីព្រោះត្រឹមអភិបាលមនោនេះធ្វើការធំមានស្គាល់គេច្រើន មានអំណាចនៅតែមិនដឹងប្ដឹងម៉េចឈ្នះ ព្រោះគ្មានភស្តុតាង!»

«ភស្តុតាងមានន័យថាម៉េចទៅ?!»

«ហ៊ឹម....មានតែអ្នកនិយាយថាកូនស្រីរបស់គាត់មានជំងឺសរសៃប្រសាទ ចំណែកអ្នកសិក្សាដែលរៀបការទៅនោះព្រោះតែស្រឡាញ់ទ្រព្យសម្បត្តិគ្រួសារនេះ មិនមែនស្រឡាញ់អ្នកក្រវ៉ាន់ទេ! យកកូនគាត់ទៅដាក់ច្រវាក់ឬបិទជិតឃុំក្នុងបន្ទប់! អត់បាយអត់ទឹកស្លាប់ នេះមិនរាប់ថាត្រូវប្ដីធ្វើបាបឱ្យស្លាប់ទេ?»

ពិតជាហួសហេតុសម្រាប់ទទួលយកការភ្ញាក់ផ្អើលមួយនេះ។

«កូនស្រីគាត់ពិតជាមានជំងឺសរសៃប្រសាទមែនឬក៏យ៉ាងណា?!»

«ខ្ញុំក៏មិនដឹងដែរសែហ្វអើយ! ខ្ញុំបានចួបនាងតែម្ដងគត់នៅពេលនាងអាយុបីឆ្នាំ ប៉ុន្តែធ្លាប់ឮគេនិយាយថា នាងអាចមានជំងឺដូចគ្នាតពូជពីម្ដាយ! ម្ដាយនាងស្លាប់បាត់ពេលសម្រាលបានបីឆ្នាំដោយមិនមានអ្នកណាដឹងមូលហេតុពិតទេ!»

«ចុះបានន័យថា អ្នកក្រវ៉ាន់ស្លាប់ជាងដប់ឆ្នាំហើយ?!»

«ចាំ!»

ចូចលូកមាត់សួរទាំងមុខស្លេកៈ

«តែលោកអ៊ំ! ឥឡូវនេះ បីខែថ្មីៗ មានអ្នកបម្រើក្នុងផ្ទះស្លាប់ជាបន្តបន្ទាប់ គឺផ្ទះដែលប្ដីអ្នកក្រវ៉ាន់រស់នៅ! អ្នកភូមិនៅក្បែរៗនិងអ្នកបម្រើក្នុងផ្ទះ បែរជាចោទថាបណ្ដាលមកពីគំនូរធំមួយនៅក្នុងផ្ទះរបស់អ្នកក្រវ៉ាន់!»

«គំនូរ? គំនូរអ្វី?!»

«ជារូបគាត់! អ្នកក្រវ៉ាន់គាត់កាន់ចង្កៀងមួយដើរចេញពីស៊ុមក្បាច់!»

យាយនៅគិត រាប់ដៃជើង។ អធិការគ្រហែមនិយាយឡើងៈ

«មានគេទាមទារឱ្យប៉ូលិសដុតចោលរូបនោះដោយនិយាយថា ជាបណ្ដាសាចាស់ដែលធ្វើឱ្យអ្នកក្រវ៉ាន់ដើរចេញមកបានរាល់ថ្ងៃរនោចណ៎ាអ៊ំ!»

ស្រ្តីជរាដដែលនេះរបូតកែវតែពីដៃបែកខ្ទាយ ធ្វើឱ្យចូចថយមកក្រោយខ្នងប្រធានដូចជាភ័យ។

និមលវិញក៏គ្រហែមលេបទឹកមាត់ភ័យដែរ ប៉ុន្តែខំប្រឹងសួរៈ

«អ៊ំប្រហែលជាដឹងរឿងនេះហើយមែនទេ?!!»

«រឿងអ្វីទៅក្មួយ?!»

«ពាក្យចចាមអារ៉ាមដែលគេនិយាយថា ឪពុករបស់គាត់ ហេតុតែស្រឡាញ់លើកូនស្រីខ្លួនពេក! ពេលកូនស្លាប់ក៏បានរកគ្រូខ្មែរដាក់បណ្ដាសាលើគំនូរមួយឱ្យកូនស្រីគាត់អាចមានមហិទ្ធិឫទ្ធិចេញមកក្រៅបានរៀងរាល់រនោចពីដប់បីដល់ដប់ប្រាំ?!»

ស្រ្តីគ្រវីក្បាលទុក្ខព្រួយពេញផ្ទៃមុខ។ គាត់ចរចាឆ្លើយៈ

«ខ្ញុំបានឮគេនិយាយថា អភិបាលមនោពិតជាបានប្រមូលទ្រព្យសម្បត្តិយកទៅរកគ្រូហ្មគ្រប់ទីកន្លែង ប៉ុន្តែរឿងគំនូរនោះសូម្បីតែឃើញក៏ខ្ញុំមិនដែលឃើញផង បើសិនជាមែន វាពិតជាកម្មពៀរខ្លាំងណាស់ ខ្ញុំមិនដឹងរឿងអីទៀតទេ អស់លោកឈប់សួរខ្ញុំទៅ!»

ទាំងបីនាក់ចៅហ្វាយនិងកូនចៅចាកចេញមកក្រៅវិញ។

ការចួបជាមួយដូនចាស់ នៅបង្កប់មកតាមជាមួយចម្ងល់ជាច្រើននៅក្នុងគំនិតពួកគេ។

«យល់យ៉ាងណានិមល?!»

និមលនិយាយតបៈ

«មានរបាយការណ៍ផ្សេងទាន!!»

«កុំបង្អង់យូរ និយាយមក!»

និមលអាននិងពន្យល់ៈ

«ចាប់តាំងពីមុននេះ អភិបាលមនោនេះគឺជាមនុស្សចម្លែក! គាត់មានប្រពន្ធតែហាមមិនឱ្យចេញពីផ្ទះ! មានកូនស្រីមួយ ក្រោយប្រពន្ធស្លាប់បាត់គាត់រស់នៅជាមួយកូនស្រីរហូតមិនរៀបការប្រពន្ធថ្មី ហើយក្រោយមកកូនគាត់បានស្លាប់ទៀត! ពេលនោះគាត់ក៏ពិតជាប្រមូលលក់ទ្រព្យសម្បត្តិចាកចេញពីស្រុកកំណើត ដើរហើរមិនដឹងរសាត់ទៅដល់ណាខ្លះទេ! ក្រោយមកទៀតគាត់ត្រូវបានគេរកឃើញស្លាប់នៅនៅជិតទល់ដែនឡាវ! ស្លាប់ទាំងមិនបានផ្ទេរមរតក ដីស្រែចម្ការទៅឱ្យអ្នកណាទាំងអស់ ឬសូម្បីតែកូនប្រសាប្រុសរបស់ខ្លួន!!»

«គាត់ស្លាប់បាត់មែន?!»

«មានរបាយការណ៍ឯកសារប៉ូលិស និយាយពីការបូជាសពរបស់គាត់ដោយអ្នកស្រុកឆ្ងាយ!»

ទុំនាងចាប់ផ្ដើមវាយតម្លៃ៖

«បើសិនជាអភិបាលមនោពិតជាបានចាកចេញពីផ្ទះស្វែងរកគ្រូហ្មមែន គាត់ប្រាកដជាបានវិលមកវិញជាមួយគំនូរនោះ? បើមិនអ៊ីចឹងបានពីណាយកមកឱ្យប្ដីរបស់អ្នកស្លាប់តាំងទុកក្នុងផ្ទះ?!»

ចូចនិងបុលនៅស្ងៀម។ អធិការក៏តឿនសួរ៖

«រកសៀងសក្តិម្នាក់នោះឃើញឬនៅ?!»

ចូចឆ្លើយវិញ៖

«កំពុងតែព្យាយាមបន្តទៀត ឮសូរថាគេចទៅរស់នៅជាមួយនឹងម្ដាយចាស់ដែលខេត្តកំពង់ចាម!»

«ហេតុអីបានជាផ្ទះមានរឿងរ៉ាវមិនមកដោះស្រាយ បែរជាទៅរស់នៅជាមួយម្ដាយចាស់ទៅវិញ?!» នាងនិយាយហើយចេញបទបញ្ជា៖

«ស្អែកយើងទៅកំពង់ចាម!» អធិការបញ្ជា។